WASHINGTON STATE BOARD OF HEALTH

HEALTH EQUITY
Governor's Interagency Council on Health Disparities

# ការវាយតម្លៃផលប៉ះពាល់សុខភាព – សេចក្ដីផ្ដើម

https://youtu.be/Fe59CxyttNk?feature=shared (ជាភាសាអង់គ្លេស)

សួស្តី នាងខ្ញុំឈ្មោះ Lindsay ហើយនាងខ្ញុំជាផ្នែកមួយនៃក្រុមការងារដែលសរសេរការវាយតម្លៃផលប៉ះពាល់សុខភាព (ឬ H-I-R)។ HIR គឺជាការវិភាគដែលមានគោលដៅ និងមិនប្រកាន់បក្សពួក ដែលប្រើភស្តុតាងដើម្បីកំណត់ថាតើសំណើថវិកា ឬសេចក្តីព្រាងច្បាប់ណាមួយអាចប៉ះពាល់យ៉ាងណាខ្លះចំពោះសុខភាព និងសមភាពនៅក្នុងរដ្ឋវ៉ាស៊ីនតោន។ HIR ផ្តល់ឱ្យបុគ្គលធ្វើការសម្រេចចិត្តនូវព័ត៌មានពាក់ព័ន្ធនឹងគោលនយោបាយ ដែលបានមកពីកម្រងសំណួរអំពីសុខភាព និងសមភាព។

សមាជិកសភាគ្រប់រូប ឬអភិបាលរដ្ឋវ៉ាស៊ីនតោនអាចស្នើឱ្យធ្វើ HIR បាន ហើយអាចធ្វើទាក់ទងនឹងគ្រប់ប្រធានបទគោលនយោបាយ ដរាបណាសំណើនោះមិនទាន់អនុម័តជាច្បាប់។ យើងចាំបាច់ត្រូវបញ្ចប់ការធ្វើ HIR ក្នុងរយៈពេល 10 ថ្ងៃ ក្នុងអំឡុងសម័យប្រជុំសភា និងកាន់តែមានភាពបត់បែនក្នុងការកំណត់ពេលរបស់យើង នៅពេលអង្គនីតិបញ្ញត្តិមិនស្ថិតក្នុងសម័យប្រជុំ។

សមាជិកសភាអាចស្នើឱ្យធ្វើ HIR ដោយសារហេតុផលជាច្រើន។ សមាជិកសភាមួយចំនួនអាចប្រើលទ្ធផលរកឃើញពី HIR ដើម្បីស្វែងយល់អំពីផលប៉ះពាល់ដែលអាចមានប្រសិនបើសំណើណាមួយក្លាយជាច្បាប់ ពិភាក្សាអំពីសំណើណាមួយជាមួយសហការី ឬធ្វើការកែប្រែទៅលើសំណើណាមួយ។

HIR ដែលបានធ្វើរួចរាល់ទាំងអស់មាននៅលើគេហទំព័ររបស់ក្រុមប្រឹក្សាសុខាភិបាលរដ្ឋ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ www.sboh.wa.gov/hir (ជាភាសាអង់គ្លេស)។